# ដីកាបញ្ជាសំរាប់ការពារ(គ្រប់សំណុំរឿង)
# ORDER FOR PROTECTION (All Cases)

នេះជាដីកាបញ្ជាពិតប្រាកដ ដែលចៅក្រមចុះហត្ថលេខា ។ ដីកាបញ្ជានេះ ត្រូវទុកនៅក្នុងសំណុំរឿងសំរាប់ តុលាការ ។ អ្នកត្រូវយកសេចក្តីចម្លងដែលបញ្ជាក់ថាត្រឹមត្រូវនៃ ដីកាបញ្ជានេះ ពីស្មៀនតុលាការ ដើម្បីបង្ហាញដល់ប៉ូលីស ។

ចូរបំពេញឈ្មោះ ជាបដ្តនាការជន,ហើយចុះខែ/ថ្ងៃ/ឆ្នាំកំណើតរបស់អ្នក ត្រង់កន្លែងដែលនិយាយថា(ខែ/ថ្ងៃ/ឆ្នាំកំណើត) ។ ចូរបំពេញឈ្មោះនិងខែ/ថ្ងៃ/ឆ្នាំកំណើត របស់ចុងចោទ ។ បើអ្នកមិនដឹងខែ/ថ្ងៃ/ឆ្នាំកំណើតទេ,ចូរចុះអាយុនៃចុងចោទ ។

**បើមិនមានជាប់ទាក់ទងនឹងក្មេងក្រោមអាយុទេ,**ចូរគូសប្រអប់ថា "មិនមានក្មេងក្រោមអាយុរួមឡើយ" ។

**បើមានជាប់ទាក់ទងនឹងក្មេងក្រោមអាយុ**,ចូរចុះឈ្មោះ,អាយុ,ពូជសាសន៍ ហើយនិងភេទ នៃក្មេងនិមួយៗ ដែលរួមជាមួយនៅក្នុងសំណុំរឿង ។

[ ចៅក្រមនឹងបំពេញអ្វីដែលនៅសល់នៃក្រដាសពាក្យ] ។
[ ចូរគូសប្រអប់ដូចគ្នា ដែលអ្នកបានគូសនៅលើក្រដាសបដ្តនាលិខិត] ។

[ពត៌មានតទៅនេះ មានទាក់ទងដល់ចំណុចទីបី និងទីបួនហើយនិងទីដប់ប្រាំ,មានតែៈ ចំណុចទីបី, កំរិតហាមឃាត់ចុងចោទ មិនឲ្យទៅជាន់ដី ឬចូលទៅផ្ទះអ្នក,មានចន្លោះទុកឲ្យអ្នកសរសេរ អាសយដ្ឋានទីលំនៅរបស់អ្នក ។ អ្នកមានសិទ្ធិរក្សាអាសយដ្ឋានទីលំនៅរបស់អ្នក ដោយអាថិកំបាំង(សម្ងាត់) ។ គេមិនតម្រូវឲ្យអ្នកសរសេរចុះ អាសយដ្ឋានទីលំនៅរបស់អ្នកឡើយ បើអ្នកមានកង្វល់អំពីសន្តិសុខ ឬអំពីការលួចយកអត្តសញ្ញាណប័ណ្ណរបស់អ្នក ។ ថ្វីបើយ៉ាងនេះក៏ដោយ,ការបង្ខំខាងផ្លូវច្បាប់នៃបញ្ជានេះ អាចមានភាពស្រួលជាង បើអ្នកបានបញ្ចូលអាសយដ្ឋានរបស់អ្នកផង ។ បើអ្នកសំរេចថា បញ្ចូលអាសយដ្ឋានរបស់អ្នក,ចូរចុះអាសយដ្ឋានឲ្យបានសព្វគ្រប់ ព្រមទាំងក្រុងផង ។

ចំណុចទីបួន,ផ្តល់សិទ្ធិទាំងស្រុង សំរាប់ទីលំនៅ ដែលអ្នកហើយនិងជនឆ្លើយចែកគ្នានៅ,មានកន្លែងចំហរទុកឲ្យអ្នកសរសេរអាសយដ្ឋានទីលំនៅបានចែកគ្នា ។ អ្នកមានសិទ្ធិរក្សាអាសយដ្ឋានទីលំនៅរបស់អ្នកដោយ អាថិកំបាំង (សម្ងាត់) ។ គេមិនតម្រូវឲ្យអ្នកសរសេរចុះ អាសយដ្ឋានទីលំនៅរបស់អ្នកឡើយ បើអ្នកមានកង្វល់អំពី សន្តិសុខ ឬអំពីការលួចយកអត្តសញ្ញាណប័ណ្ណរបស់អ្នក ។ ថ្វីបើយ៉ាងនេះក៏ដោយ,ការប្រតិបត្តិដីកាបញ្ជានេះ អាចមានភាពស្រួលជាង បើអ្នកបានបញ្ចូលអាសយដ្ឋានរបស់អ្នកផង ។ បើអ្នកសំរេចថា បញ្ចូលអាសយដ្ឋានរបស់អ្នក,ចូរចុះអាសយដ្ឋានឲ្យបានសព្វគ្រប់ ព្រមទាំងក្រុងផង] ។

បន្ទាប់ពីចំណុចទីដប់ប្រាំ,ស្តីពីការទៅសួរសុខទុក្ខនៃចុងចោទ ជាមួយនិងកូន,មានច្បាប់មួយស្តីពីការដូរកន្លែងក្មេង (Child Relocation Act) ។ បើច្បាប់ប្រគល់សិទ្ធិឲ្យអ្នកគ្រប់គ្រងក្មេង ហើយអ្នកមានផែនការចង់ដូរកន្លែងជាមួយក្មេង,អ្នកត្រូវប្រាប់ចុងចោទ ឲ្យដឹងថា អ្នកដូរទីកន្លែងក្មេងហើយ ។ ចុងចោទ អាចមានសិទ្ធិនិងជំទាស់ ចូរទាក់ទងក្រឡាបញ្ជី,អ្នកសំរួលការងារនៃមន្ទីរតុលាការ,ឬទាក់ទងអ្នកគាំទ្រហឹង្សាគ្រួសារ ដើម្បីពត៌មានស្តីពីសិទ្ធិរបស់អ្នក ហើយនិងមុខការទាំងឡាយ មានចែងក្រោមច្បាប់ the Child Relocation Act] ។

ប្រអប់ពត៌មាននៅខាងក្រោមបង្អស់ នៃទំព័រលេខបី ព្រមានជនឆ្លើយតបអំពីលក្ខណៈ ដែលអាចកើតមាន ប្រសិនបើចុងចោទបំពានលើដីកាបញ្ជានេះ ។

## ជំនួយក្រសួងមានសមត្ថកិច្ច

ចូរគូសប្រអប់ឲ្យត្រឹមត្រូវ ហើយបំពេញត្រង់ភ្នាក់ងារក្រសួងមានសមត្ថកិច្ច ឲ្យគេដឹងំ **ទីកន្លែងដែលអ្នករស់នៅ** ដើម្បីឲ្យគេអាចចុះ ដីកាបញ្ជានេះនៅក្នុងសម្ព័ន្ធកុំព្យូទ័រពេញរដ្ឋទាំងមូល ។

ចូរគូសប្រអប់ឲ្យត្រឹមត្រូវ ហើយបំពេញត្រង់ភ្នាក់ងារក្រសួងមានសមត្ថកិច្ច ឲ្យគេដឹង **ទីកន្លែងដែលចុងចោទរស់នៅ** ដើម្បីឲ្យគេអាចចុះ ដីកាបញ្ជានេះនៅក្នុងសម្ព័ន្ធកុំព្យូទ័រពេញរដ្ឋទាំងមូល ។

ចូរគូសប្រអប់ត្រូវគ្នា អំពីការបំរើនៃដីកាបញ្ជានេះ ។

បើអ្នកត្រូវការជំនួយពីប៉ូលិស ដើម្បីឲ្យបានចូលទៅក្នុងទីលំនៅរបស់អ្នក,ចូរគូសប្រអប់នោះ ។

បើអ្នកត្រូវការជំនួយ ដើម្បីឲ្យបានវត្ថុជាកម្មសិទ្ធិផ្ទាល់ខ្លួនអ្នក,ចូរគូសប្រអប់នោះ ហើយនិងប្រអប់ ដែលបង្ហាញថា កម្មសិទ្ធិទាំងនោះ នៅក្នុងទីលំនៅថ្លៃលគ្នា,ទីលំនៅរបស់ចុងចោទ ឬនៅកន្លែងផ្សេងទៀត ។ (អ្នកត្រូវទាក់ទងទីភ្នាក់ងារក្រសួងមានសមត្ថកិច្ចក្នុងតំបន់អ្នក ដើម្បីណាត់ពេលឲ្យក្រសួងមាសមត្ថកិច្ចអាចជួយអ្នក) ។

បើអ្នកចង់ឲ្យគេជួយ ដើម្បីបានទទួលការគ្រប់គ្រងកូនរបស់អ្នក,ចូរគូសប្រអប់នោះ ។ (មានការតឹងតែងណាស់ អំពីច្បាប់ដែលមានសមត្ថកិច្ចអាចធ្វើបាន ។ ចូរទាក់ទងទីភ្នាក់ងារក្រសួងមានសមត្ថកិច្ចប្រចាំបន់អ្នក) ។

បើអ្នកចង់ឲ្យគេជួយ ឲ្យបានរថយន្ត ដែលតុលាការបានចេញបញ្ជាឲ្យអ្នកប្រើ,ចូរគូសប្រអប់នោះ ។

ចូរគូសប្រអប់ "ផ្សេងៗ" បើអ្នកត្រូវការជំនួយបន្ថែម ហើយរៀបរាប់អំពីប្រភេទនៃជំនួយនោះ ។

បើអ្នកមានសំណួរ អំពីដីកាបញ្ជានេះ,ចូរសួរក្រឡាបញ្ជី,អ្នកសំរួលការងារនៃមន្ទីរតុលាការ ឬអ្នកគាំទ្រហឹង្សាគ្រួសារ ។

ចូរចុះហត្ថលេខានៅក្រដាសពាក្យខាងក្រោម ត្រង់កន្លែងនិយាយថា "បានបង្ហាញដោយ" និង "បដ្ឋនាជន" ហើយចុះខែ/ថ្ងៃ/ឆ្នាំផង ។ ចុងចោទនឹងចុះហត្ថលេខាផងដែរ បើចុងចោទ បានចូលរួមសវនាការ ហើយមិនមានការបំរើចាំបាច់ក្រៅទៀតទេ ។

តទៅនេះគឺជាតំណាងនៃដីកាបញ្ជា សំរាប់ការពារ:

# តំណាង

| | |
|---|---|
| **តុលាការវ៉ាស៊ិនតោន សំរាប់** | លេខៈ |
| ______ បដ្ឋទាជន ______ ខែ/ថ្ងៃ/ឆ្នាំកំណើត<br>vs.<br>______ ចុងចោទ ______ ខែ/ថ្ងៃ/ឆ្នាំកំណើត | **ដីកាបញ្ជា សំរាប់ការពារ**<br>(ORPRT) (គ្រប់សំណុំរឿងទាំងអស់)<br>(តម្រូវឲ្យមានសកម្មភាពរបស់ស្បៀន)<br>អាសយដ្ឋានតុលាការ: ______<br>______<br>លេខទូរស័ព្ទ: (   ) ______ |

តុលាការមានគណៈវិនិច្ឆ័យលើភាគីទាំងអស់,ក្មេងក្រោមអាយុ ហើយនិងរឿងនិមួយៗ ។ □. បើក្មេងក្រោមអាយុចូលរួមផង, រដ្ឋនេះមាន □ បន្តគណៈវិនិច្ឆ័យទាំងស្រុង □ ជារដ្ឋខ្លួន; □ មិនមានរដ្ឋក្រៅ មានការបន្តគណៈវិនិច្ឆ័យទាំងស្រុង;
□ ផ្សេងៗ ______

លិខិតសវនាការនេះ បានផ្តល់ដល់ចុងចោទ ដោយ □ ហុចផ្ទាល់ □ ផ្ញើតាមប៉ុស្តិ៍ យោងតាមបញ្ជាតុលាការ □ ការបោះពុម្ពផ្សាយសាធារណៈ យោលទៅលើបញ្ជាតុលាការ □ ផ្សេងៗ ______
______

តុលាការបានចេញដីកាបញ្ជានេះ យោលតាមសភាពពិតហើយនិងកិច្ចសន្យាផ្នែកកិត្តិយសនៃច្បាប់ VAWA: 18 U.S.C. § 2265.

អត្តសញ្ញាណប័ណ្ណនៃក្មេងក្រោមអាយុ: □ មិនមានក្មេងក្រោមអាយុរួមឡើយ ។

| ឈ្មោះ (ខ្លួន,កណ្តាល,អក្សរដើម,ត្រកូល) | អាយុ | សាសន៍ | ភេទ |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

យោលទៅលើបដ្ឋទាលិខិត,សាក្សី,និងឯកសារសំណុំរឿង,តុលាការរកឃើញថា ចុងចោទ បានប្រព្រឹត្តហឹង្សាគ្រួសារ ដូចមានចែងនៅត្រង់ RCW 26.50.010 ហើយបង្ហាញថាមានការគំរាមកំហែង ទៅលើសន្តិសុខរាងកាយរបស់បដ្ឋទាការជនដែលគួរឲ្យជឿ,**ហើយតុលាការបានចេញដីកាថា**:

| | |
|---|---|
| | 1. ចុងចោទត្រូវច្បាប់ហាមឃាត់ពីការធ្វើឲ្យបដ្ឋទាការជន មានគ្រោះថ្នាក់,របួសខូចប្រាណ,វាយតប់,ការរំលោភផ្នែកភេទ,ហើយនិងព្យាបាទ,ប្រើពាក្យអសុរោះ គំរាម,ឬឈ្លបចាប់ដល់ □ បដ្ឋទាជន □ ក្មេងក្រោមអាយុមានឈ្មោះត្រង់តារាងខាងលើ □ តែក្មេងក្រោមអាយុប៉ុណ្ណោះ: |

| | |
|---|---|
| | 2. ចុងចោទ ត្រូវបានកំរិតមិនឲ្យមកក្បែរ ឬទាក់ទងតាមប្រការណាមួយ,ទោះជាផ្ទាល់បុគ្គល ឬតាមរយៈជនដទៃ, តាមទូរស័ព្ទ, សំបុត្រ,ឬតាមមធ្យោបាយណាមួយ ទោះជាដោយចំពោះ ឬមិនចំពោះ,លើកលែងតែការផ្ញើ ឬការបំរើនៃទំរង់ការនៃឯកសារតុលាការ ដោយ ភាគីទីបី ឬទាក់ទងមេធាវី របស់ចុងចោទ ជាមួយ □ បដ្ឋនាការជន<br>□ ក្មេងក្រោមអាយុមានឈ្មោះត្រង់តារាងខាងលើ □ តែក្មេងក្រោមអាយុទាំងនេះប៉ុណ្ណោះ:<br><br>បើភាគីទាំងពីររស់នៅកន្លែងជាមួយគ្នា,ចុងចោទ ត្រូវតែចាកចេញ ។ |
| | 3. ចុងចោទ មិនត្រូវចូលទៅក្នុងទីលំនៅ □ បដ្ឋនាជន □ កន្លែងធ្វើការ □ សាលារៀន; □ មន្ទីរថែទាំ ឬសាលាលារៀន □ របស់ក្មេងមានឈ្មោះនៅតារាងខាងលើ □ តែក្មេងក្រោមអាយុប៉ុណ្ណោះ:<br><br>□ ផ្សេងៗ<br>□ អាសយដ្ឋានបដ្ឋនាជន ត្រូវទុកជាអាថិកំបាំង □ បដ្ឋនាការជនបដិសេធភាពអាថិកំបាំងនៃអាសយដ្ឋានរបស់ខ្លួន ដែលជា: |
| | 4. បដ្ឋនាជនត្រូវមានសិទ្ធិទាំងស្រុង ទៅលើទីលំនៅ ដែលបដ្ឋនាជន និងចុងចោទនៅចូលគ្នា ។ ចុងចោទ **ត្រូវចេញ** ពីផ្ទះនោះជា បន្ទាន់ ។ បដ្ឋនាជន អាចយកសំលៀកបំពាក់ជាកម្មសិទ្ធិ ហើយនិងឧបរករណ៍របស់ខ្លួន ចេញពីទីលំនៅ នៅពេលដែលក្រសួងមានសមត្ថកិច្ច កំពុងនៅទីនោះ ។<br>□ អាសយដ្ឋាននេះ ត្រូវទុកជាអាថិកំបាំង ។ □ បដ្ឋាទាការជន បានបដិសេធភាពអាថិកំបាំងនៃអាសយដ្ឋាននេះ ដែលជា: |
| | 5. ចុងចោទ ត្រូវហាមឃាត់ពីចេតនាមកនៅ,ឬរក្សាចេតនារស់នៅក្នុងរវាង ________________________ (ចម្ងាយ)នៃ: បដ្ឋនាជន □ ទីលំនៅរបស់បដ្ឋនាការជន □ កន្លែងធ្វើការ □ សាលារៀន □ កន្លែងមើលក្មេង ឬសាលារៀននៃ □ ក្មេងក្រោមអាយុទាំងនេះប៉ុណ្ណោះ:<br><br>□ ផ្សេងៗ: |
| | 6. បដ្ឋនាជន ត្រូវទទួលរបស់ជាកម្មសិទ្ធិចាំបាច់,រួមទាំងដូចតទៅ: |
| | 7. បដ្ឋនាជន បានប្រគល់សិទ្ធិប្រើរថយន្តដូចតទៅ:<br>ឆ្នាំ,ម៉ាក,ម៉ូដែល ____________________________________ លេខឡាន: ____________________ |
| | 8. ផ្សេងៗ: |
| | 9. ចុងចោទត្រូវចូលរួមក្នុងការព្យាបាល ហើយនិងឱវាទ ដូចតទៅ:<br>□ កម្មវិធីសិក្សាខាងហឹង្សាគ្រួសារផ្អែកឧក្រិដ្ឋកម្ម ដែលបានយល់ព្រមនៅក្រោមច្បាប់ RCW 26.50.150 ឬ ឱវាទណែនាំនៅ: ____________________<br>□ ថ្នាក់ឪពុកម្តាយនៅ: ____________________<br>□ ការព្យាបាលគ្រឿងញៀន/សុរានៅ: ____________________<br>□ ផ្សេងៗ: |

| | |
|---|---|
| | 10. បដ្តទាជនត្រូវឲ្យប្រាកដតាមការវិនិច្ឆ័យទល់និងចុងចោទចំនួន $______________សំរាប់ថ្ងៃឈ្នួលហើយនិងតម្លៃផ្សេងៗ ។ |
| | 11. ភាគីទាំងអស់ត្រូវត្រឡប់មកតុលាការវិញនៅ ________________________, ម៉ោង ________ ព្រឹក/រសៀល ដើម្បីធ្វើការសើរើពិនិត្យឡើងវិញ ។ |
| ចូរបំពេញ ប្រសិនបើដីកាបញ្ជា ទាក់ទងទៅនិងរឿងក្មេង | |
| | 12. បដ្តទាជន ត្រូវទទួលការគ្រប់គ្រងក្មេង,ត្រួតត្រាបណ្តោះអាសន្ននូវ □ ក្មេងក្រោមអាយុមានឈ្មោះត្រង់តារាងខាងលើ □ តែក្មេងក្រោមអាយុទាំងនេះប៉ុណ្ណោះ: |
| | 13. តុលាការបានហាមឃាត់មិនឲ្យចុងចោទ ជ្រៀតជ្រែកអាណាព្យាបាលក្មេងផ្នែកផ្លូវកាយ ឬផ្លូវច្បាប់របស់បដ្តទាជនដែលគ្រប់គ្រង<br>□ ក្មេងក្រោមអាយុមានឈ្មោះនៅតារាងខាងលើ □ តែក្មេងក្រោមអាយុទាំងនេះប៉ុណ្ណោះ: |
| | 14. តុលាការបានហាមមិនឲ្យចុងចោទយកក្មេងចេញពីរដ្ឋ □ ក្រោមអាយុមានឈ្មោះនៅតារាងខាងលើ<br>□ តែក្មេងក្រោមអាយុទាំងនេះប៉ុណ្ណោះ: |
| | 15. តុលាការនឹងអនុញ្ញាត ឲ្យចុងចោទមកជួបសួរសុខទុក្ខដូចតទៅ: ______________________<br>________________________________________<br>________________________________________<br>________________________________________<br>________________________________________<br>________________________________________<br>________________________________________<br>________________________________________<br>បដ្តទាជន អាចស្នើសុំ ដូរការមកជួបបាន បើចុងចោទ មិនបានយល់ព្រម ចូលរួមក្នុងការព្យាបាល ឬផ្នែកឱវាទណែនាំឲ្យស្រប តាមដីកាបញ្ជាតុលាការ ។ |
| **បើជនដែលក្មេងនៅជាមួយច្រើនជាងគេ មានផែនការនិងដូរទីលំនៅក្មេង,ជននោះត្រូវធ្វើឲ្យបានស្របតាមលិខិតតម្រូវ នៃច្បាប់ the Child Relocation Act ។ ជនដែលមានសិទ្ធិជួបក្មេង តាមបញ្ជាតុលាការ អាចជំទាស់និងសំណើដូរទីលំនៅនេះបាន ។ ចូរមើលច្បាប់ RCW 26.10 ឬ RCW 26.26 ដើម្បីបានពត៌មានច្រើនទៀត ។** | |

**ការព្រមានដល់ចុងចោទ:** ការបំពានលើកិច្ចសន្យានៃដីកាបញ្ជាពិត ដែលមានលិខិតបញ្ជាក់ពីរយៈពេលរបស់គេ គឺជា ឧក្រិដ្ឋកម្ម នៅក្រោម Chapter 26.50 RCW ហើយគេនឹងចាប់ចង ជនប្រព្រឹត្តបំពាននេះ ។ ប្រសិនបើការបំពាននៃកិច្ចការពារ បានឆ្លងផុតពីព្រំដែនរដ្ឋ ឬហួសពីគណៈវិនិច្ឆ័យនៃកុលសម្ពន្ធ ឬចូលរួមក្នុងរវាងព្រំដែនទឹក ហើយនិងគណៈវិនិច្ឆ័យនៃសហរដ្ឋអាមេរិក, ដែលរួមចូលទាំងដីរបស់កុលសម្ពន្ធ, ចុងចោទអាចត្រូវជាប់ពិរុទ្ធលើឧក្រិដ្ឋកម្ម នៅក្នុងតុលាការសហព័ន្ធ នៅក្រោមច្បាប់ 18 U.S.C. §§ 2261,2261A, ឬ 2262 ។

ការបំពានលើដីកាបញ្ជានេះ គឺជាទោសបទមជ្ឈិមទាំងបំពាន លុះត្រាតែអនុវត្តទាក់ទងទៅនិងករណីណាមួយ ចំណោមករណីដូចតទៅនេះ: ការវាយតប់ណាមួយ ដែលជាការបំពាន ទៅលើដីកាបញ្ជានេះ ហើយការវាយតប់មិនចាត់ចូលទៅក្នុងកំរិតទីមួយ ឬទីពីរ នៅក្រោម ច្បាប់ RCW 9A.36.001 ឬ 9A.36.021 គឺជាឧក្រិដ្ឋកម្មថ្នាក់ C ។ ដំណើរការនៃការបំពាននៃដីកាបញ្ជានេះ ដែលជាការ ធ្វេសប្រហែស ហើយធ្វើឲ្យមានគ្រោះថ្នាក់ដល់ស្លាប់ ឬមានរបួសរាងកាយយ៉ាងធ្ងន់ ដល់ជនណាមួយ គឺជាឧក្រិដ្ឋកម្មថ្នាក់ C ។ ម្យ៉ាងទៀត,ការបំពាននៃដីកាបញ្ជានេះ គឺជាឧក្រិដ្ឋកម្មថ្នាក់ C បើចនឆ្លើយតប មានទោសពីមុន យ៉ាងតិចបំផុតត្រឹមពីរដង ដោយការ បំពានលើច្បាប់ការពារ ដែលបានចេញទៅឲ្យនៅក្រោមច្បាប់ Title 10,26 ឬ 74 RCW ។

ដីកាការពារនេះ មានប្រសិទ្ធិភាពជាបន្ទាន់ ហើយនិងបន្តរហូតណា ដីកាការពារនេះ នៅតែមានប្រសិទ្ធិភាព,ចុងចោទ មិនអាចមានកាំភ្លើង ហើយនិងគ្រាប់រំសេវឡើយ ។ 18 U.S.C. § 922(g)(8) ។ ការបំពាននូវច្បាប់កាំភ្លើងនៃសហពន្ធ អាចនាំឲ្យពិន័យទោសជាប់គុក អាចដល់ទៅចំនួន១០ឆ្នាំ ហើយនិងត្រូវពិន័យជាប្រាក់ដល់ទៅ $250,000 ។ ចំពោះក្រសួងមានសមត្ថកិច្ច ហើយនិងបុគ្គលិកយោធា ដែលនឹងត្រូវលើក ។

**អ្នកអាចត្រូវគេចាប់ចងបាន ទោះបីជាជនណាមួយ ដែលបានទទួលដីកាបញ្ជា បានប្រាប់ឬអនុញ្ញាត ឲ្យអ្នក បំពានលើដីកាបញ្ជាហាមឃាត់នេះក៏ដោយ** ។
អ្នកជាជនតែម្នាក់ឯងគត់ ដើម្បីទទួលភារៈកិច្ច ក្នុងការគេចឲ្យផុត ពីការបំពាន លើកិច្ចសន្យារបស់ដីកាបញ្ជានេះ ។ មានតែតុលាការទេ ដែលអាចដូរដីកាបញ្ជានេះ យោលទៅពាក្យសុំជាលាយលក្ខណ៍អក្សរ។

យោលទៅលើច្បាប់ 18 U.S.C. § 2265 ,តុលាការក្នុងរដ្ឋណាមួយ ចំណោមទាំង៥០រដ្ឋ, the District of Coumbia, Puerto Rico, ដែនដីសហរដ្ឋ, និងដីកុលសម្ពន្ធ ក្នុងសហរដ្ឋ ត្រូវយល់ស្របតាមដីកាបញ្ជានេះទាំងអស់ ។

---

នេះជាបញ្ជាទៅថ្ងៃមុខថា ក្រឡាបញ្ជី ត្រូវបញ្ជូនសេចក្តីចម្លង នៃដីកាបញ្ជានេះ នៅថ្ងៃ ឬមុនថ្ងៃធ្វើការវិនិច្ឆ័យលើកក្រោយឲ្យទៅ ______________________ ☐ ការិយាល័យប៉ូលីស ☐ ក្រសួងប៉ូលីស **ដែលបដ្ឋទាជនរស់នៅ** ដែលគេត្រូវចុះនៅក្នុងកុំព្យូទ័រ-យោលទៅលើសម្ព័ន្ធបញ្ជាវ័ន្តឧក្រិដ្ឋកម្ម ដែលមានលទ្ធភាព នៅក្នុងរដ្ឋនេះ ដែលត្រូវប្រើដោយក្រសួងមានសមត្ថកិច្ច ដើម្បីរក៍បញ្ជីរាយដីកាបញ្ជាយ៉ាងប្រសើរ ។

☐ ក្រឡាបញ្ជី ត្រូវបញ្ជូនសេចក្តីចម្លង នៃដីកាបញ្ជានេះ នៅថ្ងៃ ឬមុនថ្ងៃធ្វើការវិនិច្ឆ័យលើកក្រោយឲ្យទៅ
_☐ ការិយាល័យប៉ូលីសខៅនធី ☐ ក្រសួងប៉ូលីស **ដែលជនឆ្លើយតបរស់នៅ** ដែលគេ នឹងផ្តល់ឲ្យជនឆ្លើយតប នូវសេចក្តីចម្លងនៃដីកាបញ្ជានេះ ហើយបំពេញនឹងបញ្ជូនភ័ស្តុតាងតុលាការនេះ ឲ្យបានទាន់ពេល ។
☐ បដ្ឋទាជន បានរៀបចំដីកាបញ្ជានេះតាម ☐ ប៉ុស្តិ៍សំបុត្រ ☐ ការបោះពុម្ពផ្សាយ ។
☐ បដ្ឋទាការជន បានធ្វើការសំរួលជាឯកជន សំរាប់ទទួលដីកាបញ្ជានេះ ។
☐ ចុងចោទដែលបានមកបង្ហាញខ្លួន ហើយតុលាការក៏បានប្រាប់អំពីបញ្ជានេះហើយ;មិនតម្រូវឲ្យមានការបំរើតទៅទៀតឡើយ ។

---

☐ ទីភ្នាក់ងារក្រសួងមានសមត្ថកិច្ច កន្លែងដែល ☐ បដ្ឋទាជន ☐ ជនចុងចោទរស់នៅ ត្រូវជួយបដ្ឋទាជន ឲ្យបានទទួលយក:
☐ ជួយបដ្ឋទាជន ឲ្យបាន
☐ ទីលំនៅរបស់ ☐ បដ្ឋទាជនវិញ ☐ កម្មសិទ្ធិផ្ទាល់ខ្លួន ដែលតាំងនៅ: ☐ ផ្ទះរស់នៅចូលគ្នា ☐ ផ្ទះរបស់ចុងចោទ
☐ ផ្សេងៗ: ______________________.
☐ ការគ្រប់គ្រងក្មេងក្រោមអាយុដែលមានឈ្មោះ,មានការថែទាំខ្លួនប្រាណ សំរាប់យកទៅឲ្យបដ្ឋទាជន ។
☐ ប្រើរថយន្ត ដែលបានចាត់តាំងមកខាងលើ ។
☐ ផ្សេងៗ: ______________________
☐ ផ្សេងៗ: ______________________

**ដីកាបញ្ជាសំរាប់ការពារនេះ ត្រូវផុតអានុភាពទៅ ______________________ [ខែ/ថ្ងៃ/ឆ្នាំ]** ។

បើរយៈពេលនៃដីកាបញ្ជានេះ លើសពីមួយឆ្នាំ,តុលាការរកឃើញថា ដីកាបញ្ជានោះតិចជាងមួយឆ្នាំ
នឹងមិនមានពេលគ្រប់គ្រាន់ដើម្បីការពារ អំពើហឹង្សាគ្រួសារតទៅទៀតឡើយ ។

បានចុះនៅ ______________________ ម៉ោង ______________________ ព្រឹក/រសៀល ។

______________________
ចៅក្រម/គណៈកម្មាធិការតុលាការ

បានបង្ហាញដោយ:

ខ្ញុំទទួលស្គាល់បង្កាន់ដៃនៃសេចក្តីចម្លងដីកាបញ្ជានេះ សំរាប់ការពារ:

______________________
បដ្ឋទាជន ខែ/ថ្ងៃ/ឆ្នាំ

______________________
ចុងចោទ ខែ/ថ្ងៃ/ឆ្នាំ